Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

សំណុំទឹកឃ្មុំ ២/២ (មេសា ២០០១)៖ ១-៩



# ទំពាំងស្នងឫស្សី

អ៊ួន សិលា

នៅក្នុងប្រទេសជាច្រើននៅទ្វីបអាស៊ីនេះ ឫស្សីជារុក្ខជាតិដែលមានប្រយោជន៍ជាទីបំផុត គឺមានប្រយោជន៍លំដាប់ទីពីរ បើប្រៀបទៅនឹងដើមត្នោត ។ កសិករខ្មែរខ្លះបានហៅដើមត្នោត និងដើមឫស្សីថាជាប្ដីនិងប្រពន្ធ គឺមានន័យថាគេត្រូវការគ្នាទៅវិញទៅមក ដើម្បីផលិតស្ករត្នោត ។ កសិករខ្មែរប្រើដើមឫស្សីធ្វើជាបង្អោង( *បង្អោងតែក/បង្អែកតោង*) សំរាប់ឡើងដើមត្នោត និងប្រើសំរាប់ធ្វើជាបំពង់ទឹកត្នោត ដើម្បីត្រងយកទឹកត្នោត ។

ឫស្សីគឺមានប្រយោជន៍តាំងពីឫសរហូតដល់ស្លឹក ។ គេបានយកទំពាំងមកប្រើធ្វើជាម្ហូប ។ គេប្រើដើមឫស្សីសង់ផ្ទះ ខ្ទម ប្រក់ជាដំបូល ធ្វើល្អី កញ្ចើ កញ្ជ្រោង ដងសន្ទូច និងរនាបគ្រែដេក ប្រើធ្វើជាបំពង់ដាក់ទឹក (*សំរាប់ជនជាតិភាគតិច*) ធ្វើជាចង្កឹះ ឈើចាក់ធ្មេញជាដើម ។

លើសពីនោះទៅទៀត ប្រើជានិមិត្តសញ្ញា ដើម្បីប្រៀបធៀបទៅក្មេងៗជំនាន់ក្រោយ ។ ពាក្យស្លោករបស់ខ្មែរយើង មួយឃ្លាពីបូរាណ

ពោលថា៖ "*ទំពាំងស្នងឫស្សី*" គឺមានន័យថា ឫស្សីចាស់ត្រូវស្លាប់ខ្លះ ត្រូវគេកាប់រិចដល់ដីមានតែពឹងពាក់ទំពាំងដុះថ្មីទើបគុម្ពឫស្សីអាចស្ថិតនៅបាន ។ នៅក្នុងគម្រោងកម្មវិធីរបស់ អង្គការទស្សនៈពិភពលោកកម្ពុជា មានគម្រោងកម្មវិធីមួយនៅក្បែរផ្សារថ្មី ធ្វើការជាមួយក្មេងអនាថា ដែលមានឈ្មោះថា "*ទំពាំងស្នងឫស្សី*" ។

ជនជាតិវៀតណាមប្រើឫស្សីជានិមិត្តសញ្ញា ដើម្បីបង្រៀនដល់សិស្សសាលារបស់គេ ។ នៅក្នុងប្រទេសចិនឫស្សីគឺមានប្រជាប្រិយ៍មែនទែន ពីព្រោះគេប្រើវាដើម្បីធ្វើជាចង្កឹះកាលពីសម័យដើម ។ ធ្មេញជនជាតិចិន ខាំលើដើមឫស្សីរៀងរាល់ពេល នៅពេលដែលទទួលទានអាហារ! ពួកវិចិត្រករជនជាតិចិនជារឿយៗបានគូររុក្ខជាតិឫស្សី នៅក្នុងគំនូរគ្រប់ប្រភេទរបស់គេ ។ គ្រីស្ទបរិស័ទចិនប្រើឫស្សីជានិមិត្តសញ្ញា បញ្ជាក់ពីជំនឿរបស់គេនៅក្នុងរឿង ខ្សែភាពយន្តមួយឈ្មោះថា "*ឫស្សីនាសិសិររដូវ*" (*Bamboo in the Winter*) ។

ក្នុងនាមជាគ្រីស្ទបរិស័ទខ្មែរម្នាក់ ខ្ញុំចង់ប្រើដើមឫស្សីណែនាំដល់លោកអ្នកស្តីពីគោលការណ៍ខ្លះៗពីជំនឿគ្រីស្ទបរិស័ទរបស់យើង ។ ក្នុងការធ្វើបែបនោះ គឺខ្ញុំព្យាយាមធ្វើតាមជំហានព្រះអម្ចាស់របស់យើង ។ ចំពោះសាសន៍យូដា ព្រះអម្ចាស់យេស៊ូវរបស់យើង ដកស្រង់យកពីក្រឹត្យវិន័យរបស់លោកម៉ូសេមកបង្រៀន ចំពោះអ្នកនេសាទ ព្រះអង្គបង្រៀនពីការនេសាទត្រី ចំពោះពួកកសិករ ព្រះអង្គបង្រៀនអំពីរឿងប្រៀបប្រដូចអំពីគ្រាប់ពូជ ចំពោះអ្នកប្រាជ្ញដូចជាលោកនីកូដេម ព្រះអង្គលើកយកពីទស្សនៈវិជ្ជាមកបង្រៀន ឯចំណែកស្ត្រីនៅក្បែរអណ្តូងវិញ ព្រះអង្គប្រើវត្ថុសាមញ្ញដែលអ្នកស្តាប់របស់ព្រះអង្គ ធ្លាប់ដឹងរួចមកហើយនោះ ។ នេះឯងគឺអ្វីដែលខ្ញុំនឹងធ្វើដូចគ្នានោះដែរ ។ ដោយសារតែលោកអ្នកទាំងអស់ធ្លាប់ស្គាល់រួចមកហើយនោះ ខ្ញុំនឹងប្រើវា ដើម្បីជំរាបជូនលោកអ្នក (*ខ្ញុំមិនហ៊ានប្រើពាក្យថា "បង្រៀន" នោះឡើយ*) ពីរបៀបដែល

យើងត្រូវផ្សាយព្រះរាជសាររបស់ព្រះជាម្ចាស់ តាមបែបមួយ ដ៏សមរម្យ ហើយអាចទទួលយកបានតាមទំនៀមទំលាប់យើងផង ។

ចូរកុំព្យាយាមយកគ្រាប់តាមលោកគ្រូមកពីបស្ចិមប្រទេស ឬពួកបេសកជនឲ្យដូចគេបេះដាក់នោះឡើយ ។ របៀបបង្រៀនរបស់គេអាចស៊ីនឹងស្ថានការណ៍របស់គេ ប៉ុន្តែប្រហែលជាមិនស៊ីនឹងស្ថានការណ៍របស់យើងទេមើលទៅ ។ នៅពេលដែលខ្ញុំនិយាយរបៀបនេះខ្ញុំមិនមែនចង់បានន័យថាខ្ញុំបន្ទាបដំណឹងល្អ បំភ្លៃដំណឹងល្អ ឬ ធ្វើឲ្យព្រះរាជសាររបស់ព្រះជាម្ចាស់ចុះខ្សោយនោះឡើយ ។ សូមមើលទៅព្រះអម្ចាស់យេស៊ូរបស់យើង នៅពេលដែលព្រះអង្គគង់នៅឯផែនដី ព្រះអង្គប្រើរបៀបផ្សេងៗតម្រូវតាមអ្នកស្តាប់របស់ព្រះអង្គដែលមានមជ្ឈដ្ឋានផ្សេងៗពីគ្នា ។ "ចូរឲ្យដំណឹងល្អរឹងមាំមានឥទ្ធិពល ចូរឲ្យគេយល់និងព្រមទទួល" ។

ខ្ញុំដឹងថាជនជាតិខ្មែរយើងចូលចិត្តកំណាព្យ ដូច្នេះហើយខ្ញុំនឹងជូនកំណាព្យដល់លោកអ្នកអានដូចតទៅ :

## ទំពាំងស្នងឫស្សី

*ពាក្យចាស់មួយឃ្លាបានពោលថា*
*លោកថាទំពាំងស្នងឫស្សី*
*ឫស្សីចាស់ៗត្រូវគេកាប់*
*ដូច្នេះត្រូវតែខំពង្រឹង*
*ឫស្សីខ្លះត្រូវរលំដួល*
*ឫស្សីខ្លះទៀតខ្យល់ផាត់ប៉ើង*
*ព្រោះឫស្សីនោះវាចេញផ្កា*
*បើឫស្សីចេញផ្កាផុលផុស*

*សូមផ្ទៀងសោតាញាតិប្រុសស្រី*
*យុវជនប្រុសស្រីគួរយល់ដឹង ។*
*ឫស្សីខ្លះស្លាប់បាត់សូន្យឈឹង*
*ទំពាំងត្រូវប្រឹងខំលូតឡើង ។*
*ខ្យល់កួចរមួលគល់រលើង*
*ខ្លះក៏ត្រូវភ្លើងឆេះបន្សុះ ។*
*សូមផ្ទៀងសោតាម្នាលស្រីប្រុស*
*ដើមឫស្សីនោះឥតប្រយោជន៍ ។*

*គេត្រូវកាប់ចោលឥតស្រណោះ*
*ឬគេត្រូវគាស់ឫសដាច់ដោច*
*ដួលដេកលើដីក្លាយជាខ្មោច*
*ត្រូវភ្លើងឆេះខ្លោចរាបដល់ដី ។*
*ឫស្សីបែបនោះប្រៀបដូចជា*
*ត្រីស្មានគ្រប់គ្នាទាំងប្រុសស្រី*
*មួយចំនួនតូចដែលគិតខ្លី*
*ពេលធ្វើការអ្វីចង់ចេញផ្កា ។*
*ឫស្សីបែបហ្នឹងប្រៀបនឹងមនុស្ស*
*ក្នុងលោកទាំងអស់គ្រប់អាត្មា*
*មានចិត្តអំនួតយ៉ាងខ្លាំងក្លា*
*ពេលចេញធ្វើការចង់ល្បីឈ្មោះ។*
*ចង់បានមុខមាត់ឬយសសក្តិ*
*ចង់បានមាសប្រាក់ដីច្រើនហួស*
*ត្រូវជាប់អន្ទាក់អារក្សអួស*
*នាំឲ្យធ្វើខុសឈ្លោះទាស់ទែង ។*
*ដោយព្រោះមានចិត្តឆ្មើងហួសល្បត់*
*នាំឲ្យហ៊ានក្បត់នឹងគ្នាឯង*
*ហ៊ានប្រព្រឹត្តឥតខ្លាចកោតក្រែង*
*ព្រោះតែខំស្វែងលាភសក្ការៈ ។*
*ពេលនោះស្រាប់តែមានរឿងធំ*
*មើលគ្នាមិនចំនាំបែកបាក់*
*ក័ណ្ឌធីម៉ូថេបានបញ្ជាក់*
*ការស្រឡាញ់ប្រាក់មិនត្រឹមត្រូវ ។*
*អួតអាងគយរមានបុកខ្ពស់*
*ពូកែខាងឈ្លោះចិត្តឃោរឃៅ*
*មិនស្តាប់បង្គាប់ដល់ម៉ែឪ*
*មានចិត្តសាហាវមិនស្មោះសរ ។*
*សូមឲ្យប្អូនៗជាទំពាំង*
*ដុះឡើងប្រឹងប្រាំងជាបន្ត*
*ក្លាយជាឫស្សីជាពូជល្អ*
*ជាពូជបវរល្អពិតជាក់ ។*
*ឫស្សីពូជល្អមានគុណភាព*
*ខ្ញុំសូមជំរាបសូមបញ្ជាក់*
*រៀបរាប់សេចក្តីជូនលោកអ្នក*
*ដោយចិត្តស្មោះស្ម័គ្រដូចតទៅ ។*
*ឫស្សីដែលល្អចេះសាមគ្គី*
*ស្រឡាញ់គ្នាគ្នីថៃកូនចៅ*
*ការពារទំពាំងយ៉ាងត្រឹមត្រូវ*
*មិនឲ្យសត្រូវមកកាប់គាស់ ។*
*ឫស្សីដុះខ្នែងចាក់ស្រេះគ្នា*
*ដើម្បីការពារក្រែងមានគ្រោះ*
*ក្រែងមានសត្រូវមកទម្លុះ*
*កកាយគាស់ឫសជីកទំពាំង ។*
*ឫស្សីអាចឈររឹងមាំបាន*
*ទោះបីជាមានភ្លៀងព្យុះខ្លាំង*
*ព្រោះដើមឫស្សីរួមកម្លាំង*
*ទើបអាចតតាំងនឹងព្យុះបាន ។*
*លក្ខណៈពិសេសគុម្ពឫស្សី*
*បងប្អូនប្រុសស្រីគ្រប់អង្គប្រាណ*
*ត្រូវតែរៀនសូត្រតាមលំអាន*
*ពេលខ្យល់រុញច្រានឫស្សីទោរ ។*
*ទន់ទាបឱនចុះស្ទើរដល់ដី*
*ក៏ដើមឫស្សីមិនដែលថ្ងូរ*
*មិនដែលអួតខ្លួនបុកគយរ*
*ស្ងប់ខ្យល់ក្រោកឈរធ្វើព្រងើយ។*

មិនដែលមើលងាយខ្លួនឯងទេ
មិនដែលជៀលជេរថាខ្លួនខ្សោយ
នេះជាគំរូត្រឹមត្រូវហើយ
ចូរកុំកន្តើយចូរធ្វើតាម ។
គំរូមួយទៀតខ្ញុំសូមប្រាប់
សូមអ្នកប្រុងស្តាប់តាមបំរាម
គំរូមួយនេះខ្ញុំសូមហាម
ចូរកុំធ្វើតាមដើមឫស្សី ។
ឫស្សីមួយគុម្ពជំនុំគ្នា
ថាយើងវេទនារៀងរាល់ថ្ងៃ
ព្រោះមានគេមកចង់ប្រល័យ
កាប់យកឫស្សីទៅប្រើការ ។
ស្រាប់តែពេលនោះមានមនុស្សម្នាក់
លីកាំបិតផ្កាក់ដាក់លើស្មា
ដើរតម្រង់មករួចកាប់ឆ្ការ
កាប់ឫស្សីតាយកមួយដើម ។
ទំរាំកាប់បានឫស្សីតា
ដៃកូតបន្លាឈាមរងើម
កាប់ចុះកាប់ឡើងបានមួយដើម
ស្ទើរផុតដង្ហើមព្រោះហត់ខ្លាំង ។
ពេលគាត់ងាកមើលមុខកាំបិត
បាត់មួយចំណិតរបេះឃ្វាំង
មុខកាំបិតគាត់ធ្លាប់ភ្លឺចាំង
បាត់អស់មួយផ្ទាំងគួរឲ្យស្តាយ ។
មានមនុស្សម្នាក់ទៀតដើរសំដៅ
ដៃកាន់ពូថៅពីចម្ងាយ
ដើរចូលមកជិតមុខរីករាយ
រួចហើយកាប់គ្រាយគុម្ពឫស្សី ។
ទម្រាំកាប់គ្រាយចូលដល់ក្នុង
ពូថៅខំលុងឥតសំចៃ
ពូថៅខំកាប់ខ្នែងឫស្សី
ខ្នែងចាស់ខ្នែងខ្ចីមានបន្លា ។
ទម្រាំកាប់បានឫស្សីរំ
ពូថៅខិតខំទាំងឈឺផ្សា
ព្រោះត្រូវទាក់មុតលើហត្ថា
ដោយសារបន្លាខ្នែងឫស្សី ។
ឫស្សីចាស់ៗពោលដូច្នេះ
កាប់របៀបនេះអញមិនភ័យ
អញព្រួយជាងគេអ្នកទីបី
មានចបផ្លែខ្ចីតែដងវែង ។
ចបជីកអាចចាក់យកទំពាំង
រលើងទាំងផ្ទាំងគួរស្ញប់ស្ញែង
ទោះបីឫស្សីអាងមានខ្នែង
មិនឈ្នះគ្នាឯងដែលជួយគេ ។
គឺព្រមធ្វើដងឲ្យផ្លែចប
ស្មគ្រព្រមប្រកបមិនងាករេ
ខំប្រឹងធ្វើការឥតទំនេរ
ស៊ីក្បត់វៀចវេរនឹងគ្នាឯង ។
នេះជាមេរៀនសំរាប់យើង
ចូរភ្ញាក់ខ្លួនឡើងឈប់សំញែង
ឈប់ធ្វើឧបករណ៍ក្បត់គ្នាឯង
ចិត្តឥតគិតក្រែងតែងថ្លោះធ្លោយ។
សាមគ្គីនាំយើងរឹងមាំជាក់
បើយើងបែកបាក់យើងចុះខ្សោយ
ពេលនោះយើងនឹងនឹកស្តាយក្រោយ
ចូរកុំកន្តើយឆាប់ចងចាំ ។

*ឱម្នាលយុវជនជាទំពាំង ចូរកុំភ្លេចភ្លាំងពាក្យផ្ដែផ្ដាំ*
*ចូរអ្នកធ្វើតាមព្រះបណ្ដាំ ចូរកុំប្រខាំទាស់ទែងគ្នា ។*
*ត្រូវស្រឡាញ់គ្នាដូចបងប្អូន ទើបសមជាកូនម្ចាស់សួគ៌ា*
*ជាព្រះអម្ចាស់យើងរាល់គ្នា ព្រះចមក្សត្រាម្ចាស់ផែនដី ។*

## ចំណុចល្អដែលយើងអាចរៀនពីដើមឫស្សី

នៅពេលដែលមានព្យុះភ្លៀងមកដល់ ឫស្សីឱនទាបមែនទែន ។ បន្ទាប់ពីផុតព្យុះភ្លៀង ដើមឫស្សីងើបឈរដូចដើមវិញដដែល ។ យើងត្រូវតែបន្ទាបខ្លួនឲ្យដូចជាដើមឫស្សីដែរ ។ យើងជាគ្រីស្ទបរិស័ទ ត្រូវការឲ្យមានឥរិយាបថបែបនោះឯង ។ អំពើបាបដែលអារក្សសាតាំងបាន ប្រព្រឹត្តនោះ គឺអំនួតនោះឯង ហេតុដូច្នេះហើយ ទើបយើងត្រូវតែខំជៀសវាងពីគំរូនេះ ម្យ៉ាងទៀតព្រះគម្ពីរបានបង្រៀនយើងថា៖ ព្រះយេស៊ូ "បន្ទាបអង្គទ្រង់ ស្ដាប់បង្គាប់ព្រះបិតាលុះក្ដីមរណា" ។ ដោយសារតែព្រះអង្គបន្ទាបអង្គទ្រង់នោះឯង ហើយទើប "ព្រះជាម្ចាស់លើកព្រះអង្គឡើងទៅកន្លែងដ៏ខ្ពស់"[១] ។ ដូចជាដើមឫស្សីដែរ ព្រះយេស៊ូឱនចុះនិងអាចងើបឈរឡើងវិញម្ដងទៀត ។ គ្រីស្ទបរិស័ទត្រូវតែយកគំរូតាមព្រះយេស៊ូ (*ដើមឫស្សី*) មិនត្រូវយកគំរូតាមអារក្សសាតាំងឡើយ ។

ដើមឫស្សីដុះជិតគ្នាចាក់ស្រេះមិនងាយរបេះពីគ្នាឡើយ ។ ការនោះហើយដែលពិបាកក្នុងការកាប់យកដើមឫស្សី ។ បើដើមឫស្សីវាដុះនៅឆ្ងាយៗពីគ្នា គឺងាយស្រួលនឹងឲ្យគេបំផ្លាញណាស់ ។ ការនេះក៏ដូចគ្នានឹងគ្រីស្ទបរិស័ទដែរ បើយើងឈរជាមួយគ្នា គាំទ្រគ្នា ជួយយកអាសាគ្នានោះ អារក្សសាតាំងពិបាកនឹងបំផ្លាញយើងណាស់ ។

---

[១] *ភីលីព ២ :៨-៩*

## ចំណុចមិនល្អដែលយើងមិនត្រូវរៀនពីដើមឫស្សី

ឫស្សីមានប្រយោជន៍យ៉ាងខ្លាំង នៅពេលដែលវាមិនទាន់ផ្កានៅឡើយ ។ បើសិនវាផ្កានោះ វានឹងចេញផ្លែ (ដូចជាផ្លែស្រងែ) ហើយពេលវាផ្លែគឺវាគ្មានប្រយោជន៍សោះឡើយ ។ ដើមឫស្សីធម្មតាគឺអាចបត់ពត់បានយ៉ាងងាយ និងស្វិតល្អទៀតផង ។ លោកអ្នកអាចយកវាមកប្រើធ្វើជាកញ្ជើ និងរបស់ដទៃទៀតដោយមិនបាក់ឡើយ ។ ប៉ុន្តែនៅពេលដែលវាចេញផ្កា ដើមឫស្សីនោះឯងនឹងទៅជាស្រួយ ហើយផុយងាយបាក់ណាស់គឺមិនអាចប្រើការបានឡើយ ។ លើសពីនេះទៅទៀតនោះ នៅពេលដែលវាចេញផ្កា ហើយនោះគឺវាឆ្លងដល់ឫស្សីដទៃទៀត ។ ដូច្នេះហើយ នៅពេលដែលវា ចេញផ្កា កសិករកាប់វាហើយដុតវាចោល ។

ចេញផ្កាតំណាងឲ្យការមានអំនួត ។ អំនួតគឺជាអំពើបាបដែលព្រះជាម្ចាស់ស្អប់ជាទីបំផុត ។ នៅពេលដែលយើងមានអំនួតពន្លកិច្ចដែលព្រះជាម្ចាស់ប្រទានឲ្យនោះនឹងមិនរីកចំរើនឡើយ ។ សេចក្តីអំនួតមិនដែលនាំមកនូវប្រាជ្ញាឡើយ ប៉ុន្តែនិស្ស័យរបស់យើងតែងតែនាំឲ្យយើងមានអំនួតមែនឬ?

ព្រះជាម្ចាស់តែងតែស្អប់អំពើអាក្រក់ ការអួតបំប៉ោង ការព្រហើន និងការពោលពាក្យបោកបញ្ឆោត[២] ។ ការអួតបំប៉ោងនាំឲ្យមានការមើលងាយ តែការបន្ទាបខ្លួនវិញនោះនាំឲ្យមានប្រាជ្ញា[៣] ។ ជម្លោះទាស់ទែងគ្នាភាគច្រើន បណ្តាលមកពីអំនួតឆ្គួតនឹងអំណាច ប៉ុន្តែប្រាជ្ញាយើងរកឃើញនៅក្នុងមនុស្សដែលព្រមទទួលនូវការទូន្មានវិញ[៤] ។ ក្នុងនាមយើងជា

---

[២] *សុភាសិត ៨ :១៣*

[៣] *សុភាសិត ១១ : ២*

[៤] *សុភាសិត ១៣ : ១០*

គ្រីស្ទបរិស័ទយើងត្រូវតែស្អប់ខ្ពើមនូវសេចក្តីអំនួត ការអួតបំប៉ោងនេះ ហើយត្រូវខំបំបាត់ចោលឲ្យអស់ បើពុំនោះទេយើងនឹងធ្លាក់ខ្លួនជាប់អន្ទាក់នៃការទាស់ទែងគ្នា ហើយនិងក្លាយជាមនុស្សដែលគ្មានប្រាជ្ញា ។ យើងអាចនឹងបដិសេធមិនទទួលនូវការផ្តល់ដំបូន្មាន ។ សុភាសិត១៦ :១៨-១៩ បានចែងថា៖ " អំនួតរមែងនាំឲ្យអន្តរាយ ចិត្តព្រហើនរមែងនាំឲ្យវិនាស ។ ដាក់ខ្លួនរស់នៅ ជាមួយជនក្រក្រីប្រសើរជាង ចែកជ័យភ័ណ្ឌជាមួយមនុស្សអួតអាង ។ " សុភាសិត២៩ : ២៣ ចែង ទៀតដែរថា៖ "អំនួតរបស់មនុស្សរមែងធ្វើឲ្យគេបាក់មុខ រីឯអ្នកដែលចូលចិត្តសុភាពរាបសាតែងតែទទួលកិត្តិយស។ "អេសាយ ២៥:១១ បានព្រមានយើងថា៖ "នៅក្នុងរណ្តៅលាមកសត្វ ម៉ូអាប់បោះដៃ ដូចគេបោះដៃហែលទឹក ប៉ុន្តែទោះបីគេខំប្រឹងយ៉ាងណាក្តី ព្រះអម្ចាស់គង់តែបំបាក់អំនួតរបស់ជនជាតិនេះជាមិនខាន ។"

ការស្រដៀងគ្នានេះដែរនៅពេលកសិករបានឃើញថា ដើមឫស្សីចាប់ផ្តើមផ្កានោះ កសិករមិនបង្អង់ឡើយ គឺកាប់ដើមឫស្សីនោះ ហើយដុតចោលភ្លាម ។ ឫស្សីមិនមែនតម្រូវឲ្យចេញផ្កាឡើយ ។ គឺមិនត្រូវចង់ធ្វើឲ្យដូចជាផ្កាកូឡាប ឬផ្កាដទៃទៀតដែលមនុស្សយកធ្វើបាច់ផ្កា និងកម្រងផ្កា ដែលគេទុកជូនអ្នកចម្រៀង និងមន្ត្រីផ្លូវការជាន់ខ្ពស់ នៅពេលដែលគេធ្វើដំណើរមកដល់វាលយន្តហោះនោះឡើយ ។ នៅពេលដែលឫស្សីចេញផ្កានោះគឺមានន័យថា ឫស្សីមានអំនួត ។

ក្នុងនាមជាគ្រីស្ទបរិស័ទ យើងត្រូវដឹងថាអំនួតនាំឲ្យមានសេចក្តីហិនវិនាស និងការទាស់ទែងគ្នា ។ ដូច្នេះយើងត្រូវតែខំជៀសវាងនូវការមានអាកប្បកិរិយា និងការប្រព្រឹត្តិបែបនោះនៅក្នុងជីវិតរបស់យើងជាប្រចាំថ្ងៃឡើយ ហើយនិងយើងដើរជាមួយព្រះជាម្ចាស់ដោយបន្ទាបខ្លួនជារៀងរាល់ថ្ងៃ ។ អាម៉ែន!

## សារុបសេចក្តី

- ដើម្បីឲ្យមានប្រយោជន៍ចំពោះកសិករ ឫស្សីមិនត្រូវចេញផ្កា និងមិនត្រូវខំព្យាយាមធ្វើខ្លួនឲ្យដូចជាផ្កាដទៃទៀតឡើយ ។
- ដើម្បីឲ្យមានប្រយោជន៍នៅក្នុងសង្គម គ្រីស្ទបរិស័ទមិនត្រូវមានអំនួតឡើយ ឬខំប្រឹងធ្វើអ្វីមួយដោយព្រោះចង់មានកេរ្តិ៍ឈ្មោះល្បីឡើយ ។
- នៅពេលដែលឫស្សីចេញផ្កាគឺមានន័យថា ឫស្សីនោះគ្មានប្រយោជន៍ទៀតឡើយ ។ ឫស្សីនោះត្រូវតែកាប់ចោល ដើម្បីឲ្យកុំឆ្លងរាលដាលដល់ឫស្សីដទៃទៀត ។
- នៅពេលដែលគ្រីស្ទបរិស័ទមានអំនួតនោះ ព្រះជាម្ចាស់មិនប្រើ ឬមិនលើកតម្កើងអ្នកនោះឡើយ ។ ព្រះអង្គនឹងបន្ទាបគេចុះ ។
- នៅពេលដែលមានសេចក្តីអំនួតអួតបំប៉ោងកើតមានឡើងនោះ នឹងធ្វើឲ្យយើងមានការបាក់បែកសាមគ្គីនៅក្នុងចំណោមគ្នាយើង !

HONEYCOMB 2/2 (April 2001): 10–15



# Bamboo

*UON Seila*

In Asian countries bamboo is a very useful plant, second in utility only to the palm tree. Some Cambodian farmers call bamboo and palm husband and wife—they need one another to produce sugar. Farmers use the bamboo as a ladder to climb the palm tree, and use it as a container to collect juice from the palm.

The bamboo is useful from root to leaves. People cook its shoots as a special food. They use it to build houses, huts, thatched roofs, baskets, fishing rods and equipment, sleeping beds, water containers (for tribal people), chopsticks, toothpicks, etc.

On top of that bamboo is used to symbolize the young generation. An old Cambodian saying states, *Tom paing snong reusey*—"Bamboo shoots take the place of the old bamboo." "Bamboo Shoot" is the name of a World Vision project that works with street children near *Psar Thmey*.

The Vietnamese use the bamboo as a symbol to teach their school students. In China bamboo is very popular. Because they use it to make chopsticks, they bite on it every day during their meals! Their artists often portray the plant in all kinds of paintings. Chinese Christians have used bamboo as a symbol for their faith in the film, *Bamboo in the Winter.*

As a Cambodian Christian I want to use the bamboo to introduce to you some of our Christian principles. In doing so I am trying to follow in our Master's footsteps. To the Jews our Lord Jesus quoted from the Mosaic Law, to fishermen He talked about catching men, to farmers He spoke a parable about seeds, to an intellectual like Nicodemus He employed a philosophical approach, and to the woman at the well He used a simple object with which she was already familiar. That is what I will do. Because you are all familiar with the bamboo, I will use it to tell you (I dare not use the word "teach" you) how to deliver God's message in an appropriate and culturally acceptable manner.

Don't try to exactly copy Western teachers or missionaries. Their approach might work in their context, but not so well in ours. When I say this I don't mean to water down the gospel or weaken the message of God. Look at our Lord Jesus—while He was on earth He used different approaches for different audiences. "Be strong with the Gospel. Be understandable to people."

I know Cambodians like poems, so I will give you one to read:

**_Shoots Take the Place of the Old Bamboo_**

*An old adage affirms what I say, so please listen carefully.*
*It says that young shoots take the place of the old bamboo.*
*This is something youth should know.*
*Old bamboo is eventually cut, and some dies away.*
*So you must strengthen yourselves.*
*You must try hard to grow up.*
*Some bamboo has fallen down.*
*Some has been blown up into the air by strong, swirling winds.*
*Some has been burned by fire because it has blossomed.*
*Please hear this, both men and women!*
*If the bamboo blossoms, it can no longer be used by the farmer.*
*He must cut it down and destroy it.*
*Bamboo that has blossomed is useless—it is fit only for the flames.*

*This kind of bamboo can be compared to some Christians.*

*A handful of them have grown narrow minded.*
*They minister only so that they may puff themselves up.*
*This kind of bamboo resembles the proud who want their names to be famous.*
*They seek personal profit, lofty status, excessive property.*
*This kind of desire is a snare set by Satan;*
*It leads people to quarrel among themselves.*
*Because of overweening pride friend betrays friend.*
*They dare to act fearlessly, for they seek to feed their greed.*
*The result is great disunity.*

*The book of Timothy says that the love of money is the root of all kinds of evil*
*Such as pride ... quarreling ... and wickedness in the heart.*
*Children don't obey their parents and their hearts are filled with dishonesty.*
*Youth are like bamboo shoots growing up continuously.*
*May you become good bamboo of the highest quality!*

*I tell you that good bamboo is united closely with each other*
*And loves each another and cares for its young.*
*They carefully protect their shoots from being cut away.*
*Bamboo grows in tight clusters to protect their young from being cut.*

*Normally bamboo can stand firmly despite rain and storm*
*Because it grows closely united together.*
*Therefore it stands unbroken by the storm.*
*We must learn from the example of the bamboo.*
*When the winds howl loud the bamboo bows down nearly to the ground.*
*They do not try to stand proud at all.*
*They rise to stand tall only when the storm passes.*
*They do not disparage their nature, as if bowing down were weak!*
*This sets a good example for us.*

*Another example—one I want to warn you against—is this:*
*Do not imitate those bamboo who unite with their enemies.*
*Once someone came to cut some bamboo.*
*But before he could cut even one his hand was bleeding.*
*He hacked away, growing breathless and tired.*
*He glanced at his knife and saw that it had been nicked.*
*His blade used to be shiny, but now one part was no longer there.*
*He felt sorry for his knife.*
*Along came another man, his axe in his hand.*
*He was so happy, and began to chop the bamboo.*
*He slashed away at the branches, but soon his hand too was bleeding.*

*The old bamboo said, "I was not worried at all*
*About the cutting these two men did.*
*But I was extremely concerned about a third man.*
*He held a short blade,*
*But it was fixed to a long handle,*
*Because one of our own Family was attached to his blade.*
*This cutting tool was very dangerous for us.*
*This kind of enemy can destroy us easily*
*Because the long handle—one of our own!—can help the blade*
*Reach through our defenses and strike us at the root."*
*This bamboo, by uniting with the enemy, helps destroy his own folk.*

*This provides a warning for us. Don't follow that example!*
*When we are united, we are strong.*
*When we are divided, we are weak.*
*Please remember this, or there will be great remorse.*

*O Youth! You are the new bamboo!*
*Remember that!*
*Don't forget God's commandments!*
*We must love one another.*
*If we love one another we can truly be called*
*God's children—children of the Lord of lords and King of kings.*

### Positive Lessons from the Bamboo

When a storm blows hard the bamboo bows down very low. After the storm passes, it stands up again as normal. We need to be humble like the bamboo. We Christians need that same kind of behavior. The worst sin Satan committed was pride; therefore we must totally avoid that pattern. On the other hand, the Bible tells us that Jesus "humbled himself and became obedient to death." Because He humbled Himself in that way "God exalted him to the highest place."[1] Like the bamboo, Jesus bowed down, and was able to stand up tall again. Christians need to follow the example of Jesus (and the bamboo), not the example of Satan.

Bamboo plants are united closely with each other. That often makes it hard to chop down an individual bamboo plant. If they all grew far apart it would be much easier to destroy them. The same is true with Christians. If we would stand close to one another, support one another, and hold one another up, it would be more difficult for our enemy Satan to chop us down.

### Negative Lessons from the Bamboo

Bamboo is most useful before it blossoms. If it does blossom it will bear fruit and become useless. Normal bamboo is flexible and tough. You can bend it easily to make baskets and other items without breaking. But after it blossoms the bamboo turns brittle and fragile. You cannot use it. Further, it will produce spores that will affect neighboring stands of bamboo. So when bamboo blossoms, it must be cut down and burned.

Blossoming is like pride. Pride is a sin that God strongly hates. When we grow proud, the ministry that God has given us will not prosper at all. Pride never produced wisdom, but our natural tendencies urge us to be proud, don't they?

God hates pride and arrogance, evil behavior and perverse speech. Pride leads to disgrace, but with humility comes wisdom. Most quarrels stem from pride, but wisdom is found in those who

---

[1]Phil 2:8–9.

take advice.[2] As Christians we must hate pride and get rid of it, or else we will become caught up in quarrels and become foolish. We may refuse to take advice. Proverbs 16:18–19 reads, "Pride goes before destruction, a haughty spirit before a fall. Better to be lowly in spirit and among the oppressed than to share plunder with the proud." Proverbs 29:23 says, "A man's pride brings him low, but a man of lowly spirit gains honor." Isaiah 25:11 warns, "They will spread out their hands in it, as a swimmer spreads out his hands to swim. God will bring down their pride despite the cleverness of their hands."

This is similar to the farmer who sees the bamboo starting to blossom. He quickly cuts it down and burns it. Bamboo is not supposed to blossom. It cannot do the same as roses or other flowers that people give to singers and officials on their arrival at the airport. When bamboo blossoms it means that it has pride.

As Christians, we must know that pride leads to destruction or quarrelsomeness. So we must avoid such attitudes and behavior in our daily lives, and walk with God humbly. Amen!

## Conclusion

- To be useful for the farmer, bamboo must not blossom and try to be like other flower plants.
- To be useful in society Christian must not puff themselves up or try to be famous.
- When the bamboo blossoms it is useless. It has to be destroyed.
- When Christians grow proud God will not use or exalt them. They will be laid low.
- When pride exists there will be disunity among us!

---

[2]Prov 8:13; 11:2; 13:10.